មន្ទីរអប់រំ ឡុងប៊ីច ធ្វើការផ្តោតលើឧត្តមភាព និង សមធម៌
ក្នុងការប្តេជ្ញាចិត្តរបស់យើង ដើម្បីបម្រើកម្មវិធីអប់រំ
ស្របតាមសេចក្តីត្រូវការរបស់សិស្សដែលមានពិការភាព។



ការិយាល័យសេវាកម្មជាជំនួយដល់សាលារៀន

សាខានៃកម្មវិធីអប់រំពិសេស

អនុវិទ្យាល័យ និង វិទ្យាល័យ

កម្មវិធីអប់រំពិសេសក្នុងមន្ទីរអប់រំ LBUSD

នៅពេលណាសិស្សបានទទួលការស្នង់វាស់មើលសមត្ថភាពហើយ គឺសិទ្ធិទទួលសេវាកម្មក្នុងកម្មវិធីអប់រំពិសេស និងអាស្រ័យលើក្រុមកម្មវិធីអប់រំលក្ខណៈបុគ្គល (IEP) ដែលមានជាមាតាបិតា និងបុគ្គលិកសាលា។ ពួកគេធ្វើការសម្រេចអំពីប្រភេទសេវាកម្មដែលសិស្សនឹងទទួល ស្របតាមតម្រូវការ តែបន្ទាប់ពីធនធានទាំងអស់នៅក្នុងកម្មវិធីអប់រំធម្មតា ត្រូវបានប្រើប្រាស់រួចរាល់អស់ហើយ។

កម្មវិធីអប់រំពិសេស គឺជាកម្មវិធីត្រូវបានបង្កើតឡើង ដើម្បីបំពេញតាមសេចក្តីត្រូវការពិសេសរបស់សិស្សដែលមានពិការភាព និងមានសិទ្ធិទទួលសេវាកម្មបាន ស្របតាមលក្ខណៈរបស់ច្បាប់។ សេវាកម្មក្នុងកម្មវិធីអប់រំពិសេស គឺអាចចាប់ផ្តើមបាននៅពេលសិស្សមានកំណើតមកភ្លាម និងបន្តរហូតដល់ពេលសិស្សមានអាយុម្ភៃពីរ (22) ឆ្នាំ។ កូនរបស់អ្នកអាចមានសិទ្ធិទទួលសេវាកម្មក្នុងកម្មវិធីអប់រំពិសេសបាន ប្រសិនបើគេមានបញ្ហាណាមួយដូចតទៅ៖

- ការនិយាយ ឬការប្រើភាសាមិនច្បាស់
- អសមត្ថភាពផ្នែកសិក្សាយ៉ាងជាក់លាក់ណាមួយ
- បញ្ហាផ្សេងៗទាក់ទងសុខភាព
- ពិការភាពអារម្មណ៍
- ពិការភ្នែក
- ថ្ងង់ អូទីស្សឹម ឬមានលក្ខណៈស្រដៀង អូទីស្សឹម
- ជំងឺឆ្អឹង
- ភាពថ្លង់
- ថ្លង់-ភាពពិការភ្នែក
- ភ្នែកមើលមិនច្បាស់ (រាប់ផងទាំងពិការភ្នែក)
- របួសខួរក្បាល
- ពិការភាពជាច្រើនមុខ

នៅមន្ទីរអប់រំ ឡុងប៊ីច ប្រសិនបើកូនរបស់អ្នកមានសិទ្ធិទទួលសេវាកម្មក្នុងកម្មវិធីអប់រំពិសេសបានមែន គឺអ្នកនឹងមានសិទ្ធិទទួលការផ្តល់ដំណឹងជូនអំពីសាលារៀនរដ្ឋ និងសាលារៀនឯកជន ឬកម្មវិធីផ្សេងៗទាំងអស់ដែលមានសម្រាប់បើកទទួលកូនរបស់អ្នក។

ច្បាប់តម្រូវឱ្យមន្ទីរអប់រំ LBUSD ដោយស្របតាមកាលៈទេសៈដ៏ត្រឹមត្រូវជាទីបំផុត ជាក់សិស្សមានពិការភាពរៀនជុំសិស្សផ្សេងៗដែលគ្មានពិការភាព។ ការដាក់ឱ្យសិស្សរៀនជារបៀបនេះ ជួនកាលហៅថា "បរិយាកាសធូរជាទីបំផុត" ("LRE")។

តទៅនេះ គឺជាបញ្ជីនៃឈ្មោះកម្មវិធីដែលមានសម្រាប់ជាការជម្រើសនិងចាប់ផ្តើមឡើង ពីបរិយាកាសធូរជាទីបំផុត រហូតដល់បរិយាកាសតឹងរឹងជាទីបំផុត៖

- ថ្នាក់រៀនធម្មតាសម្រាប់សិស្សជាទូទៅ
- ថ្នាក់រៀនធម្មតាសម្រាប់សិស្សជាទូទៅ និងកម្មវិធីទទួលធនធានពីគ្រូឯកទេស - RSP
- ការបង្ហាត់មេរៀនរួមគ្នា ដោយគ្រូបង្រៀនពីរនាក់ (ថ្នាក់ K-2) - CCT
- ការបង្ហាត់មេរៀនរួមគ្នាដែលជាការផ្តល់សេវាកម្មពិសេសដល់សិស្សមានពិការភាព (ថ្នាក់ទី 3-10) - CT
- ថ្នាក់រៀនពិសេសប្រចាំថ្ងៃ
  - ល្មម/មធ្យម - SDC M/M
  - ល្មម/ធ្ងន់ - SDC M/S
  - ពិការអារម្មណ៍ (ថ្នាក់ទី 3-12) - SDC E/D
  - S.U.C.S.E.S.S (ថ្នាក់ K-8) - S.U.C.S.E.S.S.
  - ការមើលថែសុខភាពជាលក្ខណៈឯកទេស - SDC/SPHC
  - កម្មវិធីអប់រំពិសេសសម្រាប់ថ្នាក់ត្រៀមចូលរៀន
  - ACT - កម្មវិធីអប់រំសិស្សដែលផ្ទេរវ័យជាមនុស្សធំ
- សាលារៀនឯកជន
- ការបង្ហាត់មេរៀននៅតាមផ្ទះ/មន្ទីរពេទ្យ
- កម្មវិធីអប់រំសិស្សជាជនជាតិអាមេរិកាំងដើម



Special Education Programs

SECONDARY SCHOOLS

High Schools

SCHOOL	RSP	CT**	SDC/M/M	SDC/M/S	SDC/ED	S.U.C.S.E.S.S.	SDC/SPHC
Avalon K-12 310-510-0790	X	X		X			
Browning 562-997-1700	X	X					
Cabrillo 562-951-7700	X	X	X	X	X		
CAMS 310-243-2025	X						
Jordan 562-423-1471	X	X	X	X	X		
Lakewood 562-425-1281	X	X	X	X			
McBride 562-425-7441	X						X
Millikan 562-425-3539	X	X	X	X	X		
Poly 562-591-0581	X	X	X	X	X		
EPHS 562-218-0493	X						
Reid 562-426-6846	X						
Renaissance 562-901-0168	X	X					
Sato 562-997-8115	X						
Wilson 562-433-0481	X	X	X	X	X		
ACT (Ages 18-22)			X	X			X

** CT-9·10th grades for Math and ELA

Dr. Claudia Sosa-Valderamma
ក

ការិយាល័យសេវាកម្មជាជំនួយដល់សាលារៀន

Dr. Miruna Ouatu-Lascar
វា ក

SELPA, ការឃ្លាំមើល និង ការអនុលោមតាមចិន្តនីយ

LONG BEACH
U SC T C

ការិយាល័យសេវាកម្មជាជំនួយដល់សាលារៀន

សាខានៃកម្មវិធីអប់រំពិសេស

562-997-8644